# ក្រុមមេធាវីការពារក្តីតវ៉ានឹងឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងការសួរដេញដោលលោក ឆាំង យុ


*ដោយ វ៉េនឌល ឌីហ្សាលកូ*

*ថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១២*

*ប្រែសម្រួលដោយ ហ៊ុយ សម្ផស្ស*


## *“ខ្ញុំមិនមែនជាតុលាការទេ” ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា*

នៅថ្ងៃព្រហស្បត្តិ៍ ថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបន្តសវនាការលើការធ្វើសក្ខីកម្មរបស់លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ។ នីតិវិធីថ្ងៃនេះ គឺជាការសាកសួរដេញដោល លោក ឆាំង យុ ដោយក្រុមមេធាវីការពារក្តីជនជាប់ចោទ ខៀវ សំផន និង នួន ជា ក្នុងសំណុំរឿង០០២ ។ កាលពីពេលមុននេះ អង្គជំនុំជម្រះបានណែនាំឲ្យភាគីជាច្រើន ចោទសំណួរដែលទាក់ទងទៅនឹងកិច្ចការងារអនុវត្ត និងដំណើរការប្រមូលឯកសារជាទូទៅរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។

មុនពេលថ្ងៃសួរសំណួរមកដល់ មានការយល់ច្រឡំក្នុងការបែងចែកពេលវេលារវាងក្រុមមេធាវីការពារក្តីទាំងបីក្រុម ដែលនាំឲ្យមានការផ្លាស់ប្តូរលំដាប់លំដោយ ដោយឲ្យក្រុមមេធាវីការពារក្តី ខៀវ សំផន ចោទ សួរសំណួរទៅលោក ឆាំង យុ មុនក្រុមមេធាវីការពារក្តី នួន ជា ។

ការចោទសួរលោក ឆាំង យុ ដោយក្រុមមេធាវីការពារក្តី ខៀវ សំផន។ អាកទួរ វ៉ែកគែន មេធាវីអន្តរជាតិការពារក្តី ខៀវ សំផន បានចាប់ផ្តើមសួរលោក ឆាំង យុ សម្រាប់ថ្ងៃនោះដោយពន្យល់ថា លោកនឹងផ្តោតលើឯកសារដើមពីសម័យកម្ពុជាប្រជាធិបតេយ្យ ។ លោក វ៉ែកគែន ចាប់ផ្តើមសួរលោក ឆាំង យុ ថា រវាងឯកសារដើមនឹងឯកសារចម្លង តើលោកជឿថាឯកសារណាមួយជាប្រភពព័ត៌មានដ៏ល្អបំផុត? សំណួរនេះត្រូវសហព្រះរាជអាជ្ញាជំទាស់ភ្លាមៗដោយសំអាងថា សំណួរនេះឋិតនៅក្រៅជំនាញរបស់លោក ឆាំង យុ ។ មេធាវី វ៉ែកគែន បានឆ្លើយតបដោយសំអាងថា នៅថ្ងៃដំបូងលោក ឆាំង យុ បានប្រាប់ថា មជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើការស៊ើបអង្កេតមិនមែនជាលក្ខណៈច្បាប់ ។ អង្គជំនុំជម្រះយល់ស្របនឹងការជំទាស់ ប៉ុន្តែការសម្រេចនេះមិនធ្វើឲ្យមេធាវី

វ៉ែកគែន អស់ចិត្តដោយសួររកហេតុផលថា ហេតុអ្វីបានជាមិនអនុញ្ញាតឲ្យលោកសួរសំណួរនេះ ដោយមេធាវី វ៉ែកគែន សំអាងថា លោក ឆាំង យុ គឺជាតំណាងឲ្យអង្គការមួយដែលប្រមូលឯកសារជាច្រើននៅលើពិភពលោក ហើយហេតុដូចនេះ ជំនាញលើការឲ្យតម្លៃលើប្រភេទឯកសារផ្សេងៗគ្នា គឺពិតជាឋិតនៅក្រោមការយល់ដឹងរបស់លោក ឆាំង យុ ។

ចៅក្រម ឡាវ៉ែន់ ពន្យល់ថា សំណួរបែបនេះ «មិនមែនជាដីកាទេ»ពីព្រោះវាមិនមែនទាក់ទងទៅនឹងនិតិវិធីប្ដឹងដំណើរការរបស់មជ្ឈមណ្ឌលកម្ពុជា ។ មេធាវី វ៉ែកគែន បានឆ្លើយតបថា នេះជា«ការបញ្ហា»ទាក់ទងនឹងសំណុំរឿង០០២ ពិសេសថា សំណុំឯកសារទាំងនោះបានផ្ដល់ដោយមជ្ឈមណ្ឌលកម្ពុជាត្រូវដាក់បញ្ចូលទៅក្នុងសំណុំរឿងទី២នេះ ហើយឯកសារទាំងនោះមិនបានត្រួតពិនិត្យឲ្យបានហ្មត់ចត់ទេ ។ មេធាវី វ៉ែកគែន បានសួរទៅលោក ឆាំង យុ ថា តើបច្ចុប្បន្ននេះឯកសារដើមជាច្រើនដែលលោកជឿថា ទាក់ទងនឹងសម័យកម្ពុជាប្រជាធិបតេយ្យឋិតនៅជាកម្មសិទ្ធិរបស់មជ្ឈមណ្ឌលកម្ពុជា ។ លោក ឆាំង យុ គិតមួយសន្ទុះ ហើយឆ្លើយយ៉ាងសាមញ្ញថា ឯកសារទាំងនោះ គឺនៅក្នុងប្រទេសកម្ពុជា ។ ពេលដែលសួរឲ្យចំថា ឯកសារទាំងនោះនៅទីណាឲ្យពិតប្រាកដ លោក ឆាំង យុ ប្រាប់ថា ដោយសារ«បញ្ហាសន្តិសុខ» វាពិបាកនឹងប្រាប់ទីតាំងពិតប្រាកដរបស់ឯកសារដើមទាំងនោះ ។ លោកក្រោយមកស្វែងរកការណែនាំពីអង្គជំនុំជម្រះថាតើលោកគួរពន្យល់បន្ថែមទៀត ។

បន្ទាប់មក សហព្រះរាជអាជ្ញា ធារីក អាប់ឌុលហាក់ បានជំទាស់ទៅនឹងសំណួរដោយសំអាងថា វាមាន លក្ខណៈទូលំទូលាយពីព្រោះឯកសារជាច្រើនរាប់មិនអស់ប្រហែលជាអាចដាក់នៅទីតាំងផ្សេងៗគ្នា ។ លោក ក៏បានស្នើជាយោបល់បន្ថែមទៅអង្គជំនុំជម្រះគួរតែធ្វើនៅក្នុងសវនការបិទជិត ប្រសិនបើចាំបាច់ត្រូវតែចង់ដឹងពីទីតាំងពិតប្រាកដនៃឯកសារដើមនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ។ ការស្នើនេះត្រូវបានគាំទ្រដោយក្រុមមេធាវីការពារក្ដី នួន ជា លោកម៉ៃខល ផេសមិន ដែលចង្អុលបង្ហាញថា ក្រុមមេធាវីការពារក្ដី នួន ជា មានបំណងចង់បានព័ត៌មានអំពីទីតាំងនៃឯកសារដើមទាំងនេះយ៉ាងខ្លាំង ពួកគេគ្រោងនឹងស្នើសុំឯកសារដើមមួយចំនួន ។

ចៅក្រមបានប្រជុំពិភាក្សាគ្នាបន្តិចមុនពេលបញ្ជាថា លោក ឆាំង យុ មិនចាំបាច់ឆ្លើយតបនឹងសំណួរ ដោយសារបញ្ហាសន្តិសុខ ។ លោកប្រធានអង្គជំនុំជម្រះ និល ណុន បានបញ្ជាក់ថា អង្គជំនុំជម្រះបានពិចារណាថា ក្នុងខណៈនេះមិនមានការចាំបាច់នឹងពិភាក្សាពីទីតាំងឯកសារដើម ដូចនេះការសវនាការបិទជិត មិនត្រូវបានអនុញ្ញាតនៅពេលនោះទេ ។

លោក ឆាំង យុ ក្រោយមកបានមានប្រសាសន៍ថា ប្រសិនបើភាគីណាមួយចង់ផ្ទៀងផ្ទាត់ពីឯកសារថតចម្លងថាវាត្រឹមត្រូវដូចនឹងឯកសារដើមឬទេនេះ «មជ្ឈមណ្ឌលឯកសារកម្ពុជា នឹងជួយ

សម្រួលជូន» ។ មេធាវី វែកគែន ក្រោយមកអះអាងថា “ជាការពិតណាស់លោកសាក្សី” និងបានសួរថា តើមានចៅក្រមណាមួយ ឬតំណាងការិយាល័យសហព្រះរាជអាជ្ញាណាមួយ បានស្នើសុំមជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីបញ្ជាក់ពីសុក្រឹត្យភាពនៃឯកសារចម្លងដែលបានផ្តល់ទៅឲ្យតុលាការ ។ លោក ឆាំង យុ ប្រាប់ថា លោកមិនសូវយល់សំណួរនេះច្បាស់ទេ ប៉ុន្តែ មជ្ឈមណ្ឌលឯកសារកម្ពុជានឹងអនុញ្ញាតឲ្យរាល់ភាគីទាំងអស់ មកផ្ទៀងផ្ទាត់ពីសុក្រឹត្យភាពនៃឯកសារនានាដែលផ្តល់ជូនដោយមជ្ឈមណ្ឌលឯកសាររកម្ពុជា ។ មេធាវី វែកគែន បន្ទាប់មកសួរសំណួរម្តងទៀតដោយចង់ដឹងថា តាមពិតតើមានចៅក្រម ឬក៏ការិយាល័យសហព្រះរាជអាជ្ញា ដែលទៅស្នើសុំរាល់ឯកសារដើមនានាឬទេ? លោក ឆាំង យុ បានឆ្លើយតបថា តាំងពីដើមមកមិនទាន់មាននរណាមកសុំផ្ទៀងផ្ទាត់ឯកសារដើមទេ ប៉ុន្តែមានមន្ត្រីតុលាការខ្លះ ដូចជា ស៊ីវ ហេងឌ័រ ពីការិយាល័យព្រះរាជអាជ្ញាមកសុំឯកសារពីមជ្ឈមណ្ឌលឯកសារកម្ពុជានិងស្កេនឯកសារដើមសម្រាប់ប្រើនៅ អ.វ.ត.ក ។

មេធាវី វែកគែន បន្ទាប់មកបន្តសំណួរដដែលចង់ដឹងពីបញ្ហាឯកសារដើម និងថតចម្លង និងសួរថាតើរាល់ឯកសារដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានចុះលេខនៅលើឯកសារនោះ តើវាចាំបាច់ជាឯកសារបញ្ជាក់ថា ជាឯកសារថតចម្លងមួយឬរូបភាពនៃឯកសារចម្លងមួយ? លោក ឆាំង យុ ឆ្លើយថា ឯកសាររបៀបនោះ គឺប្រាកដណាស់ជាឯកសារចម្លងពីឯកសារដើម ប៉ុន្តែដែលការិយាល័យសហចៅក្រមស៊ើបអង្កេតបានស្នើស្កេនឯកសារដើមមួយចំនួនដែលមជ្ឈមណ្ឌលឯកសារបានផ្តល់ឲ្យ ។ បន្ទាប់មក មេធាវី វែកគែន សួរលោក ឆាំង យុ អំពីការទំនាក់ទំនងរវាងការិយាល័យសហព្រះរាជអាជ្ញានឹងមជ្ឈមណ្ឌលឯកសារកម្ពុជាទាក់ទងនឹងការផ្តល់ជូនឯកសារនានា និង«សេចក្តីបញ្ជាក់ពីការចម្លងតាមឯកសារដើម» មួយពីមជ្ឈមណ្ឌលឯកសារកម្ពុជា ។ លោក ឆាំង យុ បានផ្តល់សក្ខីកម្មថា សេចក្តីបញ្ជាក់ដែលសួរនេះ ជាទម្រង់ដែលសរសេរបញ្ជាក់ថា ពីសុក្រឹត្យភាពរបស់ឯកសារដែលបានផ្តល់ជូន។ មេធាវី វែកគែន បន្តសួរថា តើមជ្ឈមណ្ឌល ឯកសារកម្ពុជាបានផ្តល់តែសេចក្តីបញ្ជាក់តែម្តង ឬក៏ផ្តល់ឲ្យគ្រប់ពេលពេលដែលមានសំណើពីការិយាល័យសហព្រះរាជអាជ្ញា? លោក ឆាំង យុ ឆ្លើយតបថា រាល់ឯកសារដែលស្នើសុំដោយការិយាល័យសហព្រះរាជអាជ្ញា មជ្ឈមណ្ឌលឯកសារកម្ពុជាបានប្រគល់នូវសេចក្តីបញ្ជាក់មួយបញ្ជាក់ថា តើឯកសារចម្លងនេះត្រូវបានចម្លងចេញពីឯកសារដើម និងបញ្ជាក់ពីសុក្រឹត្យភាពនៃឯកសារចម្លងទាំងនោះ ។

មេធាវី វែកគែន សួរទៀតថា តើលោក ឆាំង យុ គិតថា មនុស្សម្នាក់ដែលក្លែងឯកសារដែលអះអាងថា ឯកសារនោះឋិតនៅក្នុងសម័យខ្មែរក្រហមដែលអាចមិនគ្រាន់តែក្លែងបន្លំកាលបរិច្ឆេទនៃឯកសារនោះ ។ លោក ឆាំង យុ ឆ្លើយតបថា គឺជឿថា វា«មិនអាចធ្វើទៅរួច» ទេដែល

មនុស្សម្នាក់អាចនឹងក្លែងបន្លំឯកសារជាផ្លូវច្បាប់ ដែលមានព្រឹត្តការណ៍ព័ត៌មានជាប់ទាក់ទងនឹងសម័យខ្មែរក្រហមនៅពេលដែលប្រើនូវក្រដាសចំណាស់និងពាក្យពេចន៍ ឃ្លាឃ្លោង ជាក់ច្បាស់របស់ខ្មែរក្រហម ។ បន្ទាប់មក មេធាវី វែកគែន សួរថា តើមានអ្នកណាអាចក្លែងបន្លំឯកសារសម័យខ្មែរក្រហម ដោយប្រើប្រាស់ពាក្យពេចន៍ដើម្បីធ្វើឲ្យឯកសារទាំងនោះហាក់ដូចជាឯកសារពិត ។ លោក ឆាំង យុ ឆ្លើយថា មានឯកសារជាច្រើន គឺវែងណាស់ ឧទាហរណ៍ដូចជា ឯកសារចម្លើយសារភាពជាង២០០ទំព័រពីគុកទួលស្លែង ហើយវាមានការពិបាកនឹងធ្វើការក្លែងបន្លំ ឬការផ្លាស់ប្តូរណាស់ ។ លោកក៏ បានបញ្ជាក់ថា ឯកសារជាច្រើនត្រូវបានពិនិត្យដោយធ្វើការប្រៀបធៀបរវាងឯកសារមួយទៅឯកសារមួយទៀត ព្រមទាំងបានបញ្ជាក់ទៀតថា លោកគិតថា វាពិតជាពិបាកនឹងឲ្យមនុស្សម្នាក់ធ្វើការក្លែងបន្លំឯកសារជាផ្លូវច្បាប់ ។

មេធាវី វែកគែន ឆ្លើយតបថា លោកមិនបានសួរសំដៅលើឯកសារទាំងអស់ទេ ប៉ុន្តែមានឯកសារខ្លះអាចប្រហែលជាត្រូវក្លែងបន្លំ ដោយសំដៅជាពិសេសលើឯកសារមួយរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបដិសេធដោយលោក ឆាំង យុ ដែលលោកបានធ្វើសក្ខីកម្មកន្លងមក ។ លោក ឆាំង យុ ឆ្លើយតបថា ឯកសារនោះពិតណាស់ គឺខុស ប៉ុន្តែលោកបានចង្អុលបង្ហាញថា វាមិនមែនក្លែងបន្លំថា ជាឯកសារមួយនៅក្នុងសម័យខ្មែរក្រហមទេ ប៉ុន្តែវាជាឯកសារនៅក្នុងទសវត្សរ៍៩០ ។

មេធាវី វែកគែន បន្តសំណួរទៅ លោក ឆាំង យុ អំពីសក្ខីកម្មដែលលោកបានផ្តល់កន្លងមកថា លោកបានពិភាក្សាជាមួយ“ជនាញការ”វៀតណាម ។ លោក ឆាំង យុ ឆ្លើយថា លោកមិនចង់ឆ្លើយនឹងសំណួរនេះទេ ពីព្រោះលោកមិនបានចាំថា លោកបានប្រើពាក្យ“ជនាញការ” ហើយមិនចង់បញ្ជាក់ពីសំដីដែលលោកមិនបាននិយាយ ។ មេធាវី វែកគែន បន្ទាប់មកបានលើកសំណួរម្តងទៀត សួរលោក ឆាំង យុ ពីសក្ខីកម្មដែល លោក ឆាំង យុ ផ្តល់កាលពីនិយាយទៅកាន់សហចៅក្រមស៊ើបអង្កេតទាក់ទងនឹង“ជនាញការ”វៀតណាម ។ លោក ឆាំង យុ បានស្នើសុំមេធាវី វែកគែន បញ្ជាក់ពីពេលណា ដែលលោកបាននិយាយពាក្យនេះ និងសុំឲ្យមានឯកសារបញ្ជាក់ថា លោកពិតជាបាននិយាយមែន ។

ព្រះរាជអាជ្ញាបានជំទាស់នឹងសំណួរហើយស្នើថា មេធាវី វែកគែន ផ្តល់កំណត់យោងទៅនឹងឯកសារណាមួយ ប្រសិនបើចង់សម្រង់ពាក្យពេចន៍ពីសក្ខីកម្មមុន ។ លោក ឆាំង យុ ក្រោយមកបានកាត់និងឆ្លើយថា “ខ្ញុំសប្បាយរីករាយនឹងឆ្លើយសំណួររបស់លោកមេធាវី តែលោកមេធាវីមិនអាចឆ្លើយនឹងសំណួររបស់ខ្ញុំទាក់ទងនឹងការពិតនូវអ្វីដែលខ្ញុំបានលើកឡើងការពីម្សិលមិញ” ។ លោកបានបញ្ជាក់បន្ថែមថា បើសិនជាតាមការចងចាំរបស់លោក លោកបាននិយាយថា នៅក្នុងក្រសួងមហាផ្ទៃ

កម្ពុជាមានជំនាញការវៀតណាមម្នាក់ធ្វើការទាក់ទងនឹងឯកសារ ប៉ុន្តែអ្នកជំនាញការនោះបានស្លាប់ទៅហើយ ។

មេធាវី វែកគែន បានរំឭក លោក ឆាំង យុ ថាមិនមែនជាតួនាទីរបស់លោកត្រូវសួរមកកាន់មេធាវីការពារទេ ហើយលោកបានសួរទៅលោក ឆាំង យុ ឲ្យឆ្លើយសំណួរឲ្យបានច្បាស់បន្តិច ។ លោក ឆាំង យុ បន្ទាប់មកបានបញ្ជាក់ថា លោកមិនបានចាំឈ្មោះជំនាញការនោះពិតប្រាកដទេឥឡូវនេះ តែឈ្មោះរបស់ជំនាញការម្នាក់នោះប្រាកដជាមាននៅក្នុងសក្ខីកម្មមុនដែលលោកបានផ្តល់ដល់សហចៅក្រមស៊ើបអង្កេត ។ យោងទៅសំណួរបន្ថែមទៀត លោក ឆាំង យុ ផ្តល់សក្ខីកម្មថា លោកមិនបានទទួលឯកសារពី "ជំនាញការ" ម្នាក់នោះទេ ប៉ុន្តែលោកបានទទួលឯកសារពី "ក្រុមការងារ" នៅឯក្រសួងមហាផ្ទៃ ។

លោកក៏បានបញ្ជាក់បន្ថែមទៀតថា លោកចង់ឲ្យបញ្ជាក់ពីសក្ខីកម្មរបស់លោកឲ្យបានច្បាស់ថាការពិតលោកបានបញ្ជាក់សក្ខីកម្មរបស់លោកឲ្យបានច្បាស់ រួមទាំងការបកប្រែទៅភាសាបារាំងដែលមេធាវី វែកគែន កំពុងតែស្តាប់ ។

បន្ទាប់មក មេធាវី វែកគែន បានសួរអំពីឯកសារនានាដែលទទួលបានពីលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ។ លោក ឆាំង យុ ឆ្លើយតបថា លោកបានទទួលឯកសារជាច្រើនពីលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន នៅក្នុងទសវត្សរ៍៩០ ដោយពន្យល់ថា លោកបានអានសៀវភៅរបស់លោកនាយករដ្ឋមន្ត្រីនៅពេលនោះ ហើយលោកស្នើសុំថតចម្លងឯកសារយោងមួយចំនួនក្នុងសៀវភៅនោះ ។

លោក ឆាំង យុ បានត្រូវសួរសំណួរថា តើមជ្ឈមណ្ឌលឯកសារកម្ពុជាចំណាយពេលប៉ុន្មានក្នុងការប្រមូលឯកសារនានាដែលធ្វើឡើងនៅក្នុងសម័យខ្មែរក្រហម ដែលបានប្រគល់ជូន អ.វ.ត.ក ។ លោក ឆាំង យុ ឆ្លើយថា មជ្ឈមណ្ឌលឯកសារកម្ពុជានៅតែធ្វើការប្រមូលឯកសារបន្ត ហើយអ្នកដែលរស់រានមានជីវិត ក៏មជ្ឈមណ្ឌលឯកសារកម្ពុជាចាត់ទុកថាជា "ឯកសារ" ដែរ ដោយព្យាយាមសាកសួរអ្នករស់រានមានជីវិតពីសម័យខ្មែរក្រហមកាន់តែច្រើន កាន់តែល្អគឺដើម្បីរក្សាទុកនូវប្រវត្តិសាស្ត្រមួយ ។

បន្ទាប់មក លោក វែកគែន បានថ្លែងថា លោក ឆាំង យុ មិនបានឆ្លើយនឹងសំណួររបស់លោកហើយសួរ លោក ឆាំង យុ ម្តងទៀត ពីពេលវេលាដែលលោកចំណាយក្នុងការប្រមូលឯកសារជាពិសេសឯកសារដែលផ្តល់មកឲ្យអ.វ.ត.ក ។ លោក ឆាំង យុ ជាថ្មីម្តងទៀតបានផ្តល់ចម្លើយយ៉ាងវែងពន្យល់ពីការធ្វើឯកសារទាំងអស់ នៅក្នុងសម័យខ្មែរក្រហមទៅជាឌីជីថល សព្វថ្ងៃកំពុងតែសហការជាមួយសាកលវិទ្យាល័យមីឆីហ្គេន ។ លោកបានប្រាប់ថា នៅពេលអនាគតអ្នកទាំងអស់គ្នាអាចមើល

ឯកសារទាំងនេះបាន នឹងអាចមើលឃើញថា ហេតុអ្វីបានជាប្រជាជនស្លាប់នៅក្នុងសម័យខ្មែរក្រហមនេះ ។ លោកប្រធានសវនាការបានកាត់ និងរំឭកលោក ឆាំង យុ ឲ្យឆ្លើយតបឲ្យចំទៅនឹងសំណួរ ។

មេធាវី វែកគែន បានសួរលោកម្តងទៀត ។ លើកនេះ សំណួរហាក់ដូចជាច្បាស់ថា ដោយយល់ថា បញ្ហាកើតឡើងកាលពីមុនប្រហែលដោយសារការបកប្រែមិនបានត្រឹមត្រូវ ។ នៅចំណុចទីបីនៃសំណួរ លោក ឆាំង យុ ប្រហែលជាយល់នូវសំណួររបស់មេធាវី វែកគែន ចង់ដឹងថាតើមជ្ឈមណ្ឌលឯកសារ នឹងចំណាយពេលប៉ុន្មានក្នុងការប្រមូលឯកសារដើមទាំងអស់ ដែលបានផ្តល់ឲ្យទៅ អ.វ.ត.ក ប្រសិនបើមានការស្នើសុំ ។

សំណួរនេះធ្វើឲ្យសហមេធាវីអន្តរជាតិដើមបណ្តឹងរដ្ឋប្បវេណី អេលីហ្សាបេត ស៊ីម៉ុនណូ ហ្វុតជំទាស់ដោយសំអាងថា នេះមិនមែនជាតួនាទីរបស់ក្រុមមេធាវីការពារបញ្ហាឲ្យសុំរាល់ឯកសារដើម ប៉ុន្តែ មានតែចៅក្រមនៃអង្គជំនុំជម្រះតែមួយគត់ ដែលមានសិទ្ធិលើការសម្រេចនេះ ។

បន្ទាប់មក មានការជជែកវែកញែករវាងភាគីទាំងពីរ លោក ឆាំង យុ ប្រាប់ថា ប្រសិនបើអង្គជំនុំជម្រះតម្រូវឲ្យប្រគល់ជូននូវឯកសារដើមខ្លះ មជ្ឈមណ្ឌលឯកសារកម្ពុជានឹងសហការជាមួយនឹងមន្ត្រីបច្ចេកទេសរបស់ អ.វ.ត.ក ដើម្បីបង្កើតនូវវិធីសាស្ត្រសមស្របប្រកបដោយសុវត្ថិភាពមួយ ដើម្បីនាំយកឯកសារទាំងនោះ ។ ក៏ប៉ុន្តែ លោកមិនបានធ្វើការប៉ាន់ប្រមាណថាតើនឹងត្រូវចំណាយពេលវេលាប៉ុន្មានទេ ។ លោកញញឹម ហើយប្រាប់ថា ប្រសិនបើ “អ៊ុំ នួន” ចង់មើលឯកសារដើមទង់បដិវត្តន៍ លោក ឆាំង យុ នឹងសប្បាយរីករាយនឹងប្រគល់ជូនដោយផ្ទាល់ទៅតុលាការដើម្បីត្រួតពិនិត្យ ព្រោះមជ្ឈមណ្ឌលឯកសារកម្ពុជាមានឯកសារនេះច្រើនណាស់ ។

## អៀង សារី លះបង់សិទ្ធិនៅក្នុងការស្តាប់សវនាការ

ការសរុបការសួររបស់មេធាវី វែកគែន និងអង្គជំនុំជម្រះសម្រាកសម្រាប់សវនាការពេលព្រឹកនេះ ។ មុនពេលឈប់ ក្រុមមេធាវីការពារក្តីរបស់ អៀង សារី បានដាក់ឯកសារសុំលះបង់សិទ្ធិក្នុងការចូលរួមតាមដានសវនាការ និងសុំទៅស្តាប់សវនាការនៅឯបន្ទប់ឃុំឃាំងដោយ មើលដំណើរការសវនាការតាមប្រពន្ធ័សោធទស្សន៍វិញ ។ ដោយសារតែនេះជារឿងធម្មតា ហើយលោកប្រធានចៅក្រមស្នើឲ្យមេធាវីប្រគល់នូវឯកសារសរសេរបញ្ជាក់ដោយមានហត្ថលេខាពី អៀង សារី ។

## *សំណួរបន្តដោយក្រុមមេធាវី ខៀវ សំផន*

បន្ទាប់ពីសម្រាក ការសាកសួរបានបន្តដោយក្រុមមេធាវីជាតិការពារក្តី ខៀវ សំផន លោក គង់ សំអុន ដែលចាប់ផ្តើមសួរលោក ឆាំង យុ ថាតើមជ្ឈមណ្ឌលឯកសារមានបុគ្គលិកដែលមានជំនាញខាងសុក្រឹត្យភាពនៃឯកសារដែរឬទេ? លោក ឆាំង យុ ឆ្លើយថា មជ្ឈមណ្ឌលឯកសារកម្ពុជាអត់មានបុគ្គលិកជំនាញរបៀបនោះទេ ប៉ុន្តែដោយធ្វើការតាមសេចក្តីណែនាំក្នុងការប្រមូលព័ត៌មានទាក់ទងទៅនឹងឯកសារនីមួយៗ ដូចជាព័ត៌មានទាក់ទងទៅនឹងបុគ្គលដែលបានផ្តល់ឯកសារ ។ លោក ឆាំង យុ បានផ្តល់ឧទាហរណ៍ជាច្រើន ថាតើឯកសារមួយត្រូវបានរកឃើញដោយរបៀបណា និងការផ្តល់ឯកសារមកមជ្ឈមណ្ឌលឯកសារ? ឧទាហរណ៍មួយគឺអំពីរូបថតជាច្រើន ដែលបានផ្តល់ឲ្យអ្នកថតរូបជនជាតិជប៉ុន ដែលធ្លាប់នៅទីក្រុងភ្នំពេញនៅក្នុងឆ្នាំ១៩៧៩ មុនពេលដួលរលំរបស់ខ្មែរក្រហមបន្តិច ។ រូបថតទាំងនោះបានបញ្ជូនមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមស្ថានទូតជប៉ុនប្រចាំនៅកម្ពុជានៅពេលនោះ ។

បន្ទាប់មក គង់ សំអន់ សួរលោក ឆាំង យុ បន្ថែមទៀតពី ការសរសេរការណែនាំរបស់មជ្ឈមណ្ឌលឯកសារក្នុងការប្រមូលឯកសារ ។ លោក ឆាំង យុ ឆ្លើយថា ការណែនាំទាំងនេះ ត្រូវបានសរសេរព្រៀងដោយសាស្ត្រាចារ្យច្បាប់នៅសហរដ្ឋអាមេរិក ដែលសព្វថ្ងៃ ជាអគ្គរដ្ឋទូតសហរដ្ឋអាមេរិកទាក់ទងនឹងបញ្ហាឧក្រិដ្ឋកម្មសង្គ្រាម ។

លោក ឆាំង យុ ត្រូវបានសួរថា តើប្រទេសកម្ពុជាសព្វថ្ងៃមានបញ្ហាដែលតម្រូវឲ្យមានការផ្សះផ្សាជាតិក្នុងការយល់ឃើញរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ហើយថា តើគោលដៅរបស់មជ្ឈមណ្ឌលបានផ្លាស់ប្តូរទៅតាមពេលវេលាទេ ។ លោក ឆាំង យុ បានជម្រាបថា សំណួរនេះ លោកនាយករងវ៉ាន់ថាន់ ពៅដារ៉ា បានឆ្លើរួចមកហើយ តែលោកអាចនឹងឆ្លើយម្តងទៀតបើមានការចាំបាច់ ។

លោកប្រធាន និល ណុន បានប្រាប់លោក ឆាំង យុ មិនបាច់ឆ្លើយនឹងសំណួរនេះទៀតទេ ហើយបញ្ជាទៅមេធាវីការពារ គង់ សំអុន ឲ្យសួរទាក់ទងនឹងប្រធានបទ និងមិនសួរនូវសំណួរប្រចំដែរ ។ បន្ថែមពីនេះទៀត លោកប្រធានបានរំឭកដល់ភាគីទាំងអស់ថា «បេសកម្ម និងទស្សនៈវិស័យ»របស់មជ្ឈមណ្ឌលឯកសារកម្ពុជាមិនទាក់ទងទៅនឹងប្រធានបទថ្ងៃនេះទេ ។

មេធាវី គង់ សំអុន ឆ្លើយថា លក្ខខណ្ឌបានផ្លាស់ប្តូរចាប់តាំងពីឆ្នាំ១៩៩៥ នៅពេលដែលមជ្ឈមណ្ឌលឯកសារបានបង្កើតឡើង ហើយដែលចាប់តាំងពីពេលនោះមក ចលនាខ្មែរក្រហមត្រូវបានរំលាយទាំងស្រុង និងសមាជិករបស់ខ្មែរក្រហមបានចូលរួមជាមួយរដ្ឋាភិបាល ។ ដូចនេះ ក្រុមមេធាវី

ការពារគិតថា វាមានសារប្រយោជន៍ក្នុងការដឹងថា តើបេសកម្មរបស់មជ្ឈមណ្ឌលឯកសារបានផ្លាស់ប្តូរ?

## លោកប្រធានមិនបានផ្លាស់ប្តូរការសម្រេច និងបញ្ជាឲ្យក្រុមមេធាវីការពារក្តីបន្តទៅទៀត

បន្ទាប់មក គង់ សំអុន បានសួរថាតើលោក ឆាំង យុ បានតាមដានការធ្វើសក្ខីកម្មរបស់លោកនាយករង វ៉ាន់ថាន់ ពៅដារ៉ា អំឡុងពេលសវនាការសប្តាហ៍មុនឬទេ។ លោក ឆាំង យុ បង្ហាញថា លោកបានស្តាប់ផ្នែកខ្លះនៃសក្ខីកម្មរបស់លោក ដារ៉ា ហើយក៏បាននិយាយជាមួយលោក ដារ៉ា ពេលដែលបញ្ចប់ការធ្វើសក្ខីកម្មរបស់លោក។ លោក ឆាំង យុ ផ្តល់សក្ខីកម្មថា លោកបានប្រាប់លោក ដារ៉ា ថា "កុំឲ្យបារម្ភ" ពីព្រោះ វាជាការសំខាន់ក្នុងការផ្តល់ជំនួយដល់តុលាការនេះ។ លោកបានប្រាប់ទៀតថា លោកតែងតែរំឭកដល់បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាទាំងអស់ថា វាមានសារៈសំខាន់សម្រាប់ជនរងគ្រោះ ដែលធានាថា ជនជាប់ចោទទាំងអស់ទទួលបាននូវការកាត់ក្តីប្រកបដោយយុត្តិធម៌ និងក្រុមមេធាវីការពារក្តីដែលល្អ និងសំដៅទៅលើក្រុមមេធាវីការពារក្តី អៀង សារី មែនទែនការណាវាស ជាឧទាហរណ៍មួយនៃក្រុមការពារក្តីដែលមានប្រសិទ្ធិភាព។

ពេលត្រូវបានសួរពីការបែងចែកនៃឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជា លោក ឆាំង យុ បានមានប្រសាសន៍បញ្ជាក់ថា មជ្ឈមណ្ឌលកាន់កាប់ទាំងឯកសារដើម និងឯកសារដកស្រង់ពីឯកសារផ្សេងៗ ហើយការបែងចែកនេះ ជាការងាយស្រួលយល់ពីសំណាក់មនុស្សទូទៅដែលធ្លាប់ឆ្លងកាត់ការសិក្សារៀនសូត្រ ដូចជា មេធាវី គង់ សំអុន ផ្ទាល់ ដែលសក្តិសមជាមេធាវីម្នាក់។

លោកមេធាវី គង់ សំអុន ហាក់ដូចជាបង្ហាញពីការមិនពេញចិត្ត និងលើកឡើងថា កម្រិតចំណេះដឹង ឬការសិក្សា និងរឿងផ្ទាល់ខ្លួនមិនមែនជាបញ្ហា ហើយបានស្នើអង្គជំនុំជម្រះបញ្ជាឲ្យលោក ឆាំង យុ ឈប់ធ្វើការបញ្ចេញយោបល់ពីពួកគាត់។

បន្ទាប់មក លោកប្រធាន និល ណុនបានណែនាំ លោក គង់ សំអុន ឲ្យចោទសួរសំណួរឲ្យបានច្បាស់ និងរំឭកដល់រាល់ភាគីរក្សាឲ្យបាននូវការគោរពគ្នាទៅវិញទៅមកនៅក្នុងសវនាការ និងប្រើពាក្យពេចន៍ឲ្យបានសមរម្យ។

បន្តទៅសំណួរផ្សេងទៀត លោក ឆាំង យុ បានបន្តពន្យល់ពីដំណើរការវាយតម្លៃ និងបែងចែកឯកសារ។ លោកពន្យល់ថា រាល់"ការវាយតម្លៃឯកសារ" គឺធ្វើឡើងដោយលោកផ្ទាល់ ហើយត្រូវបែងចែកឯកសារសម្រាប់ទុកជាឯកសារ។

បន្ទាប់មក លោក គង់ សំអុន សួរលោក ឆាំង យុ ពី«អ្នកជំនាញ»ដែលជាបុគ្គលិក មជ្ឈមណ្ឌលឯកសារជាបន្តបន្ទាប់ទៀត។ លោក ឆាំង យុ ឆ្លើយតបថា ពាក្យថា «អ្នកជំនាញ» វាមានលក្ខណៈទូលំទូលាយណាស់ ជាពិសេសភាសាខ្មែរ។ លោកលើកឡើងថា បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា មានបទពិសោធន៍ ១៧ឆ្នាំ ក្នុងការប្រមូលឯកសារ និងបានទទួលការសិក្សាពីអ្នកជំនាញក្នុងការរក្សាឯកសារ ជាច្រើននៅសាកលវិទ្យាល័យញ៉ូសោសវេលស៍ នៅប្រទេសអូស្ត្រាលី។

នៅពេលត្រូវបានសួរម្តងទៀតទាក់ទងនឹងការធ្វើតេសលើឯកសារនានា លោក ឆាំង យុ ផ្តល់សក្ខីកម្មថា មជ្ឈមណ្ឌលឯកសារកម្ពុជាអត់មានការពិនិត្យឯកសារតាមលក្ខណៈវិទ្យាសាស្ត្រ ប៉ុន្តែមើលទៅតាមភ្នែកទទេក្នុងការពិនិត្យឯកសារ។ លោកលើកឡើងថា «ប្រសិនបើអ្នកបានហ្វឹកហាត់ភ្នែករបស់អ្នកអស់រយៈពេល១៧ឆ្នាំមកហើយ អ្នកនឹងបានដឹង»ថាតើឯកសារមួយសន្លឹកនេះជាឯកសារពិតប្រាកដក្នុងសម័យខ្មែរក្រហម ឬយ៉ាងណា។

នៅពេលដែលលោកត្រូវសួរឲ្យឆ្លើយពីការប៉ាន់ប្រមាណភាគរយនៃរាល់ឯកសារ ដែលបានប្រគល់ជូន អ.វ.ត.ក ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា លោក ឆាំង យុ លើកឡើងថា លោកមិនចង់ធ្វើការប៉ាន់ប្រមាណទេ ដូចនេះ វាប្រហែលជាការទាយស្មាន។ លោកពិតជាបានប្រាប់ថា ប្រហែលជា៦០ភាគរយនៃឯកសាររបស់ អ.វ.ត.ក ដែលត្រូវផ្តល់ឲ្យដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ប៉ុន្តែលោកមិនប្រាកដទេ នេះគ្រាន់តែជាការប៉ាន់ស្មានប៉ុណ្ណោះ។

មេធាវី គង់ សំអុន បានសួរលោក ឆាំង យុ ថាតើមានឯកសារណាមួយក្នុងចំណោមប្រហែលមួយលានឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជា អាចចាត់ទុកថា ឯកសារក្លែងក្លាយនៅពេលដែលទទួលបាន។ លោក ឆាំង យុ ឆ្លើយដោយលើកឡើងម្តងទៀតពីសក្ខីកម្មមុនដែលលោកបានប្រាប់ថា មានតែឯកសារមួយគត់ដែលត្រូវបានបដិសេធដោយ មជ្ឈមណ្ឌលឯកសារកម្ពុជារហូតមកដល់ពេលនេះ។

បន្ទាប់មកទៀត លោក គង់ សំអុន បានសួរអំពី អតីតបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាដែលសព្វថ្ងៃធ្វើការនៅអ.វ.ត.ក។ លោកឆ្លើយតបថា លោកអាចរាប់ឈ្មោះអ្នកទាំងនោះបានពីព្រោះពួកគេត្រូវបានជ្រើសរើសតាមការអនុវត្តជាលក្ខណៈស្តង់ដាររបស់អ.វ.ត.ក ដូចនេះពួកគេគួរតែមាន «មោទកភាពលើខ្លួនពួកគេ» ។

## នួន ជា លះបង់សិទ្ធិចូលរួមស្តាប់សវនាការនៅពេលនោះ

ការបញ្ចប់សំណួររបស់មេធាវីខៀវ សំផន និងអង្គជំនុំជម្រះរៀបចំសម្រាកអាហារថ្ងៃត្រង់ ។ មុនពេលចៅក្រមងើបឈរចេញពីបន្ទប់សវនាការ ម៉ៃខល ផេសមិន មេធាវីការពារក្តី នួន ជា ងើប និងលើកឡើងថា "លោកស្ទើរតែភ្លេច" ជម្រាបទៅអង្គជំនុំជម្រះថា នួន ជា ឥឡូវសុំលះបង់សិទ្ធិក្នុងការចូលរួមមើលសវនាការសម្រាប់ថ្ងៃនេះ ដោយសុំមើលសវនការតាមប្រពន្ធ័សោទស្សន៍វិញ ។ សំណើនេះត្រូវបានអនុញ្ញាតដូចធម្មតា ហើយអង្គជំនុំជម្រះរំសាយសម្រាកអាហារថ្ងៃត្រង់ ។

## ក្រុមមេធាវីការពារក្តី នួន ជា សួរទៅកាន់លោក ឆាំង យុ

នៅពេលសវនាការពេលរសៀលចាប់ផ្តើម ការសួរនេះត្រូវប្រគល់ឲ្យទៅលោក សហ្សារស្តី ប៉ៅ មេធាវីអន្តរជាតិការពារក្តី នួន ជា ដែលលោកបានថ្លែងអរគុណដល់លោក ឆាំង យុ ដែលបានផ្តល់សក្ខីកម្មក៏ដូចជាការជួយផ្តល់ឯកសារជាច្រើនដល់ក្រុមមេធាវីការពារកន្លងមក ។

បន្ទាប់មក មេធាវី ប៉ៅ បានសួរលោក ឆាំង យុ ថា នៅក្នុងមជ្ឈមណ្ឌលឯកសារកម្ពុជាសំដៅទៅលើទាំងឯកសារដើម និងឯកសារចម្លងថាជា«ឯកសារដើម»ដរាបណាឯកសារទាំងនោះបង្កើតឡើងនៅក្នុងសម័យខ្មែរក្រហម ។ លោក ឆាំង យុ បញ្ជាក់ថា នេះជាការពិត ប៉ុន្តែសូមកត់សម្គាល់ថាសម្រាប់ឯកសារចម្លងដែលកំណត់ថាដូច្នេះព្រោះ ឯកសារដើមគឺឋិតនៅក្រៅប្រទេសកម្ពុជា ។

នៅពេលដែលត្រូវសួរពីការប្រមូលឯកសារក្រោយសម័យខ្មែរក្រហម លោក ឆាំង យុ ផ្តល់សក្ខីកម្មថា មជ្ឈមណ្ឌលឯកសារកម្ពុជាមិនបានស្វែងរកនិងប្រមូលឯកសារដែលកើតឡើងក្រោយសម័យខ្មែរក្រហមទេ តែមជ្ឈមណ្ឌលឯកសារកម្ពុជាមានរក្សានូវឯកសារក្រោយសម័យខ្មែរក្រហមខ្លះដែរ នៅពេលឯកសារទាំងនោះនៅលាយលំគ្នាជាមួយឯកសារសម័យខ្មែរក្រហមដែលត្រូវបានផ្តល់មកឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជា ។

បន្ទាប់មក លោក ឆាំង យុ បានផ្តល់សក្ខីកម្មថា អ្នកស្រាវជ្រាវដូចជា លោក ប៊ែន ឃៀរនិន, ដេវីដ ឆេនល័រ និង ម្នាក់ទៀតបានធ្វើការកត់សម្គាល់លើឯកសារដើមខ្លះ ។ សំណួរផ្សេងទៀត លោក ឆាំង យុ លើកឡើងថា លោកមិនបានចាំថាតើលោក ស៊ីវ ហេឌើ បានកត់សម្គាល់លើឯកសារសម័យខ្មែរក្រហមដែលមាននៅមជ្ឈមណ្ឌលឯកសារកម្ពុជាឬទេ?

បន្ទាប់លោក មេធាវី ប៉ៅ បានសួរពីពាក្យថា "ឯកសារដែលប្រឈមនឹងគ្រោះថ្នាក់" ដែលលើកឡើងដោយលោក ឆាំង យុ កាលពីពេលមុនៗ លោក ឆាំង យុ ឆ្លើយតបថា នៅឆ្នាំ១៩៩៧

នៅក្នុងកំឡុងពេលអំពើហិង្សា និងអសន្តិសុខនៅក្នុងប្រទេសកម្ពុជា មជ្ឈមណ្ឌលឯកសារកម្ពុជាបានបញ្ជូនឯកសារជាច្រើនទៅដាក់នៅទីតាំងដែលមានសុវត្ថិភាពដោយសារបារម្ភពីបញ្ហាសន្តិសុខ ។

បន្ទាប់មក មេធាវី ប៉ៅ បានសួរអំពីគោលដៅរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា "ស្វែងរកការពិត" នៃសម័យខ្មែរក្រហមនិងសួរអំពីឯកសារមួយចំនួននិងព័ត៌មាន ដែលជាទូទៅមិនបានប្រមូលដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ។ សំណួរនេះគឺត្រូវបានជំទាស់ពីខាងព្រះរាជអាជ្ញា ដែលអះអាងថាប្រធានបទនេះមិនឋិតនៅក្នុងវិសាលភាពនៃកម្មវិធីធ្វើសក្ខីកម្មនេះ ។ មេធាវី ប៉ៅ ឆ្លើយតបថា ប្រសិនបើមានការចង់ដឹងពីដំណើរការប្រមូលឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា វាចាំបាច់ក្នុងការពិភាក្សាថាតើមជ្ឈមណ្ឌលឯកសារកម្ពុជាបានជួបប្រទះនូវភស្តុតាងនានា ដែលជាហេតុបណ្តាលឲ្យមានការស្លាប់នៅក្នុងសម័យខ្មែរក្រហម ។

អង្គជំនុំជម្រះអនុញ្ញាតឲ្យសួរសំណួរនេះហើយលោក ឆាំង យុ បានលើកឡើងថា មជ្ឈមណ្ឌលឯកសារកម្ពុជាជាការពិតបានប្រមូលឯកសារមួយចំនួនទាក់ទងទៅនឹងការទម្លាក់គ្រាប់បែកមកលើប្រទេសកម្ពុជា និងព័ត៌មានដែលនៃការស្លាប់ដែលមិនទាក់ទងទៅនឹងរបបខ្មែរក្រហម ។ ជាឧទាហរណ៍ លោក ឆាំង យុ ផ្តល់សក្ខីកម្មថា មជ្ឈមណ្ឌលឯកសារកម្ពុជាបានទទួលបានការថ្លែងពីសាក្សីជាច្រើនមកពីខេត្តស្វាយរៀង ដែលត្រូវបានទទួលរងការទម្លាក់គ្រាប់បែកយ៉ាងធ្ងន់ពីសំណាក់សហរដ្ឋអាមេរិក ។ លោកក៏បានលើកឡើងបន្ថែមទៀតថា បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាបានជួបប្រទះនឹងព័ត៌មានផ្សេងៗទៀត ដូចជាអំបែងគ្រាប់បែក និងពាក្យសម្តីរបស់សាក្សីអំពីការស្លាប់ដោយសារការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិក ឬការស្លាប់ដោយជំងឺមិនមែនដោយអំពើហឹង្សា ។

បន្ទាប់មក លោក ឆាំង យុ បញ្ជាក់ថា មជ្ឈមណ្ឌលឯកសារកម្ពុជាពិតជាបានប្រមូល និងបែកចែកព័ត៌មានទាំងអស់នោះ ហើយបានសរសេរចុះផ្សាយក្នុងទស្សនាវដ្តីស្វែងរកការពិតអំពីការឈឺចាប់ក្នុងអំឡុងពេលនោះដែលមិនមែនកើតឡើងដោយសារតែខ្មែរក្រហមទេ ។ លោកក៏បានបញ្ជាក់ផងដែរថា នៅពេលដែលមជ្ឈមណ្ឌលឯកសារកម្ពុជាសម្ភាសជាមួយអ្នករស់រានមានជីវិតសម័យខ្មែរក្រហមជាច្រើន បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាស្នើសុំឲ្យអ្នកផ្តល់បទសម្ភាសន៍រៀបរាប់ពីប្រវត្តិជីវិតរបស់គាត់មួយចប់តែម្តង ដែលជាទូទៅរៀបរាប់ពីមុនរបបខ្មែរក្រហម ។

បន្ទាប់មក មេធាវី ប៉ៅ បានសួរ លោក ឆាំង យុ ពី ទំនាក់ទំនងការងាររវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និងការិយាល័យសហព្រះរាជអាជ្ញា ។ មេធាវី ប៉ៅ បានសួរលោក ឆាំង យុ ជាពិសេសថា តើលោកបានជួបនឹងតំណាងរបស់ការិយាល័យសហព្រះរាជអាជ្ញាមុនពេលទទួលបាននូវការស្នើសុំឯកសារផ្សេងៗ ។ លោក ឆាំង យុ ឆ្លើយដោយគ្រាន់តែផ្តល់ពីការអនុវត្តជាទូទៅរបស់

មជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងការទទួល និងបំពេញនូវការស្នើសុំឯកសារ ។ នៅពេលដែល មេធាវី ប៉ៅ សួរសំណួរនោះម្ដងទៀត លោក ឆាំង យុ តបថា លោកមិនបានធ្វើការពិភាក្សាឯកសារជាមួយនឹងការិយាល័យសហព្រះរាជអាជ្ញាទេមុនពេលទទួលយកឯកសារ ក៏ប៉ុន្តែ លោកបានអនុញ្ញាតឲ្យតំណាងការិយាល័យសហព្រះរាជអាជ្ញា មកធ្វើការនៅក្នុងការិយាល័យមជ្ឈមណ្ឌលឯកសារកម្ពុជាមួយថ្ងៃក្នុង១សប្តាហ៍ដូចតែភាគីផ្សេងទៀតដែរ ។ លោក ឆាំង យុ ផ្តល់សក្ខីកម្មផងដែរថា គាត់មិនចាំបានថាលោកបានជួបលោក រ៉ូបឺត ពើទីត សហព្រះរាជអាជ្ញាអន្តរជាតិដំបូង ។ លោក ឆាំង យុ មានការភ្ញាក់ផ្អើលយ៉ាងខ្លាំងព្រោះ លោក ពើទីត គឺជា«មនុស្សមិនសូវនិយាយស្តី» ហើយគាត់មិនបាននិយាយអ្វីច្រើនទេ ។ ឆ្លើយនឹងសំណួរបន្តទៀត លោក ឆាំង យុ បដិសេធថា លោក មិនបានផ្តល់យោបល់ទៅលោក ពើទីត ក្នុងអំឡុងប្រជុំលើកដំបូងស្តីពីឯកសារដែលមជ្ឈមណ្ឌលឯកសារកម្ពុជា មានដែលអាចនឹងមានប្រយោជន៍ក្នុងដំណើរការចោទប្រកាន់ជនជាប់ចោទសំណុំរឿងទី២ទេ ។

បន្ទាប់មក មេធាវី ប៉ៅ បានសួរលោក ឆាំង យុ ថាតើលោកដឹងពីវិធីដែលការិយាល័យសហព្រះរាជអាជ្ញាជ្រើសរើសឯកសារ ។ សំណួរនេះធ្វើឲ្យព្រះអាជ្ញាជំទាស់ដោយសំអាងថាចម្លើយនៃសំណួរនេះ គឺមិនឋិតនៅក្រោមការយល់ដឹងរបស់ លោក ឆាំង យុ ។

ការបដិសេធនោះមានប្រសិទ្ធិភាពអង្គជំនុំជម្រះអនុញ្ញាតឲ្យមេធាវី ប៉ៅ បន្ត សួរថាតើការិយាល័យសហព្រះរាជអាជ្ញា បានសួរមជ្ឈមណ្ឌលឯកសារសម្រាប់ឯកសារដែលមជ្ឈមណ្ឌលអត់មានដែលឬទេ? លោក ឆាំង យុ ពន្យល់ថា លោកមិនបានពិភាក្សាឯកសារជាមួយតំណាងការិយាល័យសហព្រះរាជអាជ្ញា ប៉ុន្តែ មជ្ឈមណ្ឌលគ្រាន់តែទទួលសំណើរផ្សេងៗពីការិយាល័យសហព្រះរាជអាជ្ញាសុំឯកសារដែលមាននៅក្នុងនិន្នន័យរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។

បន្ទាប់មក លោក ឆាំង យុ បានបដិសេធថាមជ្ឈមណ្ឌលឯកសារកម្ពុជាមិនបានវិភាគ ឬវាយតម្លៃថា តើឯកសារទាំងនោះមានបង្ហាញថាមានទោស ឬគ្មានទោស ព្រមជាមួយនឹងជនជាប់ចោទសំណុំរឿង០០២ ។ នៅពេលដែលមេធាវី ប៉ៅ ជំរុញបញ្ហានេះ ព្រះរាជអាជ្ញាលើកឡើងថា ទស្សនៈរបស់លោក ឆាំង យុ លើប្រធានបទនេះមិនជាប់ពាក់ពន្ធ័ទៅនឹងទទួលយកបាននៃឯកសារទេ ។

## បន្ទាប់មក អង្គជំនុំជម្រះបានពន្យល់ជាសង្ខេបមុននឹងទទួលស្គាល់ការជំទាស់នេះ ។

បន្ទាប់មក លោក ប៉ៅ សួរថាតើមជ្ឈមណ្ឌលឯកសារកម្ពុជាចង់ឲ្យបុគ្គលជាក់លាក់ណាមួយត្រូវបានកាត់ទោសនៅពេលដែលអនុវត្តការងារគាំទ្រការបង្កើតតុលាការឯករាជ្យមួយ ។ សំណួរនេះធ្វើឲ្យមានការជំទាស់មួយទៀតពីការព្រះរាជអាជ្ញាដែលអះអាងថាសំណួរនេះមិនជាប់ទាក់ទងនឹងប្រធានបទ ។

បន្ទាប់មក លោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ ស្នើថា មេធាវី ប៉ៅ សួរឡើងវិញ ឲ្យច្បាស់គ្រាន់តែចង់ដឹងរាល់សេចក្តីថ្លែងការណ៍ជាសាធារណៈរបស់លោក ឆាំង យុ ជាតំណាងផ្លូវការ របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជានាយកនៃមជ្ឈមណ្ឌលនេះ ហើយជាពិសេសលើតែសេចក្តីថ្លែងការណ៍នានាដែលទាក់ទងនឹងអ្នកដែលគួរតែត្រូវបានកាត់ទោសដោយ អ.វ.ត.ក ។ មេធាវី ប៉ៅ លើកឡើងថា លោកនឹងមានការ«សប្បាយរីករាយ» ប្រសិនបើសំណួរដ៏ជាក់លាក់មួយត្រូវបានចោទសួរទៅលោក ឆាំង យុ ។

បន្ទាប់មក ចៅក្រម ខាតវ្រ៉ាយត៍ បានញញឹមហើយបានចោទសួរទៅលោក ឆាំង យុ ដោយខ្លួនឯង ។ ឆ្លើយនឹងសំណួរនេះ លោក ឆាំង យុ លើកឡើងថា លោកបានថ្លែងជាសាធារណៈជាច្រើនដងថា «អ្នកណាដែលបានប្រព្រឹត្តបទឧក្រិដ្ឋនានា»ត្រូវតែទទួលការកាត់ទោសពី អ.វ.ត.ក ។

បន្ទាប់មក លោក ប៉ៅ បានសួរ ប្រសិនបើលោក ឆាំង យុ ធ្លាប់ថ្លែងនៅក្នុងទស្សនាវដ្តីស្វែងរកការពិតថា នួន ជា គួរត្រូវបានកាត់ទោស ។ លោក ឆាំង យុ បញ្ជាក់ថា នេះគឺជាការពិត ប៉ុន្តែលោកមិនអាចចងចាំថាវានៅក្នុងលេខណាមួយទេ ។

ឆ្លើយទៅនឹងសំណួរទាក់ទងនឹងគោលដៅដំបូងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា និងថាតើនេះរួមទាំងជាការប្រមូលភ័ស្តុតាងសម្រាប់តុលាការ ។ លោក ឆាំង យុ ឆ្លើយថា «ខ្ញុំមិនមែនជាតុលាការទេ ខ្ញុំមិនមែនជាអ្នកស្រាវជ្រាវជាន់ខ្ពស់ទេ» ប៉ុន្តែ ខ្ញុំគ្រាន់តែជាមនុស្សម្នាក់ផ្តោត លើការប្រមូលឯកសារប៉ុណ្ណោះ ។ ក្នុងពេលរវាងសំណួរនេះ លោក ឆាំង យុ បញ្ជាក់ថា លោកបានបង្កើតសំណុំឯកសារពីបុគ្គលម្នាក់ ប៉ុន្តែ លោកបានពន្យល់ថា សំណុំឯកសារនេះត្រូវបង្កើតឡើងបន្ទាប់ពីទទួលបាននូវការស្នើសុំជាច្រើនពីសំណាក់អ្នកស្រាវជ្រាវដែលស្វែងរកព័ត៌មានពីបុគ្គលម្នាក់ៗ ។ លោកក៏បានពន្យល់ថា មានមនុស្សជាច្រើនមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីមករកព័ត៌មានទាក់ទងនឹងមន្ទីរសន្តិសុខជាច្រើន និងមន្ត្រីនៅសម័យខ្មែរក្រហមជាក់លាក់ណាមួយដូចជា អៀង សារី ជាឧទាហរណ៍ ។ ដូចនេះ លោក ឆាំង យុ បង្កើតសំណុំឯកសារទាំងនេះគឺធ្វើឲ្យមានលក្ខណៈងាយស្រួលដើម្បីផ្តល់ឯកសារដែលមានព័ត៌មានដែលរៀបចំរួចជាស្រេចដល់អ្នកស្រាវជ្រាវ ។

ក្រោយមក លោក ឆាំង យុ បានបញ្ជាក់ថាមជ្ឈមណ្ឌលឯកសារកម្ពុជាពិតជាមាន «សំណុំឯកសារ នួន ជា» និងបានបញ្ជាក់បន្ថែមទៀតថា រាល់ឯកសារដែលមានក្នុងសំណុំឯកសារនោះបានបញ្ជូនទៅផ្នែកការពារក្តីនៃ អ.វ.ត.ក ។ លោក ឆាំង យុ ក៏បានផ្តល់សក្ខីកម្មបន្ថែមទៀតថា លោកមិនចាំមិនច្បាស់ថា ពេលណាដែលសំណុំឯកសារនេះត្រូវបានបង្កើតឡើងនៅពេលណាទេ ប៉ុន្តែលោក

បានបញ្ជាក់សារជាថ្មីថា សំណុំឯកសារនេះត្រូវបានបង្កើតឡើងដើម្បីបំពេញនូវសំណូមពររបស់អ្នកស្រាវជ្រាវពីខាងក្រៅ ។

បន្ទាប់មក មេធាវី ប៉ៅ បានសួរថាតើមជ្ឈមណ្ឌលឯកសារកម្ពុជាធ្លាប់បានវិភាគពីអត្ថន័យរបស់ឯកសារក្នុងសំណុំឯកសារ នួន ជា ដើម្បីឲ្យដឹងថាឯកសារនេះមានបញ្ជាក់ពីកំហុសរបស់គាត់ ។ លោក ឆាំង យុ ឆ្លើយថា លោកមិនមែនជាមេធាវី លោកមិនចាប់អារម្មណ៍នឹងបញ្ហាច្បាប់ទេ ប៉ុន្តែចាប់អារម្មណ៍ទៅលើការស្វែងរកព័ត៌មានប្រវត្តិសាស្ត្រ ។ ប្រសិនបើលោកត្រូវការព័ត៌មានបន្ថែមដើម្បីពន្យល់ពីបរិបទ ឬទំនាកទំនងនៃឯកសារលោកស្វែងរកព័ត៌មានពីខាងក្រៅ ។

នៅពេលដែលត្រូវសួរថា តើមជ្ឈមណ្ឌលឯកសារកម្ពុជា ធ្លាប់បានប្រមូលឯកសារដើម្បីកាត់ទោសបុគ្គលណាម្នាក់ លោក ឆាំង យុ បានប្រាប់ថា មជ្ឈមណ្ឌលឯកសារកម្ពុជាគឺ«ស្វែងរកការពិត» ហើយ ដូច្នេះ លោកមានការចាប់អារម្មណ៍ចំពោះគ្រប់ឯកសារនៃរបបកម្ពុជាប្រជាធិបតេយ្យ ទោះបីជាឯកសារហាក់ដូចជាមិនសូវសំខាន់ក៏ដោយ ។ ពេលត្រូវសួរទាក់ទងទៅនឹងផ្ទាំងរូបភាពរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលមានពាក្យថា «ភស្តុតាង» នៅក្នុងនោះ លោក ឆាំង យុ បានឆ្លើយថា «ពាក្យភ័ស្តុតាង» មិនមែនប្រើតែនៅក្នុងភាសាច្បាប់នោះទេ» ដោយលោកពន្យល់វា លោកធ្លាប់បានសិក្សាផ្នែកវិទ្យាសាស្ត្រសង្គម ដែលពាក្យនេះត្រូវបានគេប្រើប្រាស់ផ្សេងៗគ្នានៅក្នុងការសិក្សាផ្នែកប្រវត្តិសាស្ត្រ ។

បន្ទាប់មក មេធាវី ប៉ៅ បានសួរពីគម្រោង«ជំរុញឲ្យមានការទទួលខុសត្រូវ»របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ លោក ឆាំង យុ ពន្យល់ថា គម្រោងនេះត្រូវបានបង្កើតឡើងក្នុងបំណងដើម្បីស្វែងយល់ពី«អ្វីដែលបានកើតឡើងក្នុងប្រវត្តិសាស្ត្រទាក់ទងទៅនឹងបទល្មើសនានាដែលបានប្រព្រឹត្តក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ» មេធាវី ប៉ៅ បានសួរថា តើមជ្ឈមណ្ឌលឯកសារកម្ពុជាបានស្វែងរកជាពិសេសនូវភស្តុតាងដែលពាក់ពន្ធ័នឹងមេដឹកនាំសម័យកម្ពុជាប្រជាធិបតេយ្យដែលបានបង្កនូវសោកនាដកម្មដូចដែលគេបានចោទប្រកាន់ ។ លោក ឆាំង យុ បានឆ្លើយថា គោលបំណងនៃគម្រោងនេះគឺដើម្បីប្រមូលព័ត៌មានសម្រាប់សវនាការដើម្បីបញ្ជាក់ឲ្យច្បាស់ថា អ្នកណាបានប្រព្រឹត្តនូវបទល្មើសក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

មេធាវី ប៉ៅ បានសាកសួរទាក់ទងទៅនឹង«ការបំភ្លឺពីការដឹកនាំ» នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលត្រូវប្រើជាគោលដៅរបស់គម្រោងជំរុញឲ្យមានការទទួលខុសត្រូវ និងសូមបញ្ជាក់ថាតើហេតុអ្វីបានជាការ«បំភ្លឺ»នេះវាមានសារៈសំខាន់អ្វីសម្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ សំណួរនេះត្រូវ

បានបដិសេធ ដោយព្រះរាជអាជ្ញាដោយលើមូលហេតុថា មេធាវីការពារក្តីបានលើកឡើងនូវដែលមិនជាប់ទាក់ទងនឹងប្រធានបទ ។

ចៅក្រមនៃអង្គជំនុំជម្រះបានពិភាក្សាគ្នាក្នុងពេលខ្លី មុននឹងបដិសេធចំពោះការជំទាស់និងបានបង្គាប់ឲ្យ លោក ឆាំង យុ ឆ្លើយនឹងសំណួរ ។

លោក ឆាំង យុ ឆ្លើយថា មជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើការស្វែងយល់ពីរចនាសម្ពន្ធ័បញ្ហានេះពីព្រោះមជ្ឈមណ្ឌលឯកសារកម្ពុជាចង់ស្វែងយល់ថា «អ្នកណាបានសម្លាប់ប្រជាជនកម្ពុជាជាងពីរលាននាក់» ។ លោកបានពន្យល់បន្ថែមទៀតថា ក្នុងពេលសម្ភាសអ្នកដែលផ្តល់បទសម្ភាសន៍មានតិចតួចណាស់ ដែលទទួលស្គាល់ថា ខ្លួនបានសម្លាប់អ្នកណាម្នាក់ក្នុងសម័យខ្មែរក្រហម ។ ដូចនេះហើយ មជ្ឈមណ្ឌលឯកសារកម្ពុជា បានធ្វើការស្រាវជ្រាវបញ្ហានេះឲ្យមានភាពស៊ីជម្រៅ ។

ក្រោយពេលសម្រាកថ្ងៃត្រង់ លោក ប៉ៅ បានបង្ហាញឯកសារសរសេរដោយលោក ឆាំង យុ ។ ពេលដែលត្រូវបានសួរទាក់ទងទៅនឹងឯកសារនោះលោក ឆាំង យុ បានពន្យល់ថា ឯកសារនេះត្រូវបានសរសេរឡើងក្នុងបំណងស្វែងយល់ពីមជ្ឈិមបក្សកម្មុយនីស្តកម្ពុជា និងគណៈកម្មាធិការអចិន្ត្រៃយ៍បក្ស និងជាការចងក្រងឯកសារក្នុងសម័យកម្ពុជាប្រជាធិបតេយ្យទុកជាឯកសារ ។ ឆ្លើយនឹងសំណួរបន្តទៀត លោក ឆាំង យុ បានផ្តល់សក្ខីកម្មថា របាយការណ៍ត្រូវបានចាត់ថាជា«ឯកសារសំងាត់» ពីព្រោះវាត្រូវប្រគល់ជូនទៅ អ.វ.ត.ក ។ លោកបានពន្យល់បន្ថែមទៀតថា មានបុគ្គលិកហាត់ការរបស់អ.វ.ត.ក បានប្រើឯកសារនេះ មិនបានត្រឹមត្រូវសម្រាប់ការងារផ្ទាល់ខ្លួនកាលពីមុន ហើយលោកចង់ធានាថា ឯកសារនានាដែលបានផ្តល់ជូនទៅតុលាការត្រូវបានប្រើប្រាស់ត្រឹមត្រូវ ។

បន្ទាប់មក លោក ប៉ៅ បានសួរ លោក ឆាំង យុ អំពីការឆ្លើយឆ្លងសារអេឡិចត្រូនិច ដែលមានរបាយការណ៍សំងាត់ពីលោក ប៉ែន ឃៀវនិន ទៅលោក ឆាំង យុ ទាក់ទងនឹងឯកសារខ្មែរក្រហមនានា ផ្សាយដោយភ្នំពេញប៉ុស្តិ៍ ។ លោក ឆាំង យុ ឆ្លើយតបថា ភ្នំពេញប៉ុស្តិ៍មានឯកសារខ្មែរក្រហមមួយចំនួនជាពិសេសរូបថត ។ លោកបានលើកឡើងបន្ថែមថា រូបថតជាច្រើននៅជាមួយនឹងឯកសារសំណេរដែលបានមកពីអន្លង់វែង ដែលជាទីតាំងដែលមានអតីតកម្មាភិបាលខ្មែរក្រហមរស់នៅ ដែលមិនអាចចូលទៅបានរហូតដល់ពេលថ្មីៗនេះ ។ លោក ឆាំង យុ បានផ្តល់សក្ខីកម្មបន្ថែមថា លោកបានទទួលរូបថត ខ្លះពីភ្នំពេញប៉ុស្តិ៍ តែមិនដែលទទួលបាននូវរាល់ឯកសារដែលលោកបានស្នើសុំទេ ។

បន្ទាប់មក មេធាវី ប៉ៅ បានសួរទៅលោក ឆាំង យុ អំពីការថ្លែងមួយក្នុងសារអេឡិចត្រូនិចមួយទៀតដែល លោកបានទទួលដែលមានរបាយការណ៍សំងាត់ ដែលលោក ក្រេក អេតឆេសាន់ បានសំដៅទៅលើ«ជនខក្រិដ្ឋសំខាន់ៗ» ។ លោក ឆាំង យុ លើកឡើងថា ឆ្លើយទៅនឹងសំណួរថា

លោក អេឆេសុន គឺជា«សកម្មជន»ដែលធ្វើការឲ្យការិយាល័យសហព្រះរាជអាជ្ញានៃ អ.វ.ត.ក ហេតុដូចនេះហើយគាត់អាចសួរ ដោយផ្ទាល់សំដៅទៅលើអតីតកម្មាភិបាលខ្មែរក្រហមណាមួយ លោក ឆាំង យុ លើកឡើងថា អ្នកសិក្សាស្រាវជ្រាវពីខ្មែរក្រហមជាច្រើនប្រដែងគ្នាទៅវិញទៅមក ហើយអ្នកស្រាវជ្រាវនិមួយៗបានបង្កើត«បញ្ជី»ផ្ទាល់ខ្លួនដែលមានបុគ្គលដែលគាត់គិតថា សមរម្យក្នុងការកាត់ទោស ។ នៅពេលដែលត្រូវសួរថា មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើត«បញ្ជី»ផ្ទាល់ខ្លួននៅក្នុងទសវត្សរ៍៩០ពីមនុស្សដែលចង់ឲ្យកាត់ទោសនោះ លោក ឆាំង យុ ឆ្លើយតបថា ដំបូងឡើង លោក ប៉ែន ឃៀរនិន គឺជា«ប្រធាន»នៃមជ្ឈមណ្ឌលឯកសារកម្ពុជាពីឆ្នាំ១៩៩៥ដល់១៩៩៦ ហើយដែលក្នុងពេលនោះ លោក ប៉ែន ឃៀរនិន បានសរសេរសៀវភៅមួយដែលរៀបរាប់ពីបុគ្គលនានាដែលលោកជឿថាសមរម្យនឹងត្រូវកាត់ទោស ។

ក្រោយមក មេធាវី ប៉ៅ បានសួរលោក ឆាំង យុ អំពីសេចក្តីថ្លែងការណ៍នៅក្នុងសារអេឡិចត្រូនិចមួយទៀតដែលមានរបាយការណ៍សំងាត់ ដែលលោក ឆាំង យុ លើកឡើងថា លោកមិនចង់បញ្ចេញឈ្មោះបុគ្គលទៅកាន់សារព័ត៌មានភ្នំពេញប៉ុស្តិ៍ ពីព្រោះមជ្ឈមណ្ឌលឯកសារកម្ពុជាមិនមាន«កម្មវិធីច្បាប់»របស់ខ្លួនផ្ទាល់ ។ សំណួរនេះក៏បានធ្វើឲ្យមានការជំទាស់មួយទៀតពីព្រះរាជអាជ្ញាដោយសំអាងថា មេធាវីការពារក្តីរបស់ នួន ជា មានបំណងចង់ចាត់ទុកមជ្ឈមណ្ឌលឯកសារកម្ពុជាថា ជាវិទ្យាស្ថានមួយ«មកកាត់ក្តី»ជាជាងចង់សំដៅគ្រាន់តែចង់ដឹងពីវិធីសាស្ត្រនានា និងដំណើរការប្រមូលឯកសារ និងផ្ទុកទុកឯកសាររបស់មជ្ឈមណ្ឌលនេះ ។

អង្គជំនុំជម្រះប្រជុំពិភាក្សាក្នុងរយៈពេលប៉ុន្មាននាទី ទើបសម្រេចទទួលស្គាល់ការជំទាស់ និងណែនាំឲ្យមេធាវី ប៉ៅ បន្តសំណួរផ្សេងទៀត ។

ក្នុងការឆ្លើយតប មេធាវី ប៉ៅ បានអានសារអេឡិចត្រូនិចមួយទៀតដែលផ្ញើពីលោក ស៊្ទីវ ហេឌើ លើកឡើងថា លោក ប៉ែន ឃៀរនិន និងមជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើខុសក្នុងការតម្រង់ការស៊ើបអង្កេតទៅតាម«ខ្សែនយោបាយ» ។ នេះធ្វើឲ្យមានការជំទាស់ជាបន្ទាន់ពីព្រះរាជអាជ្ញាដែលសំអាងលើហេតុផលថា សំណួរគឺទើបតែត្រូវអង្គជំនុំជម្រះបញ្ជាមិនអនុញ្ញាតឲ្យបន្តសំណួរបន្តិចមុននេះ ។

មេធាវី ប៉ៅ បានអះអាងថា ដើមបណ្តឹងរដ្ឋប្បវេណីបានចង់ដឹងពីបញ្ហានានាដែលអាចកើតមាននៅខាងក្រៅ ដែលអាចមានឥទ្ធិពលលើកិច្ចការរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាកាលពីថ្ងៃមុន ហើយដូចនេះ ក្រុមមេធាវីការពារក្តីក៏អាចទទួលបានសិទ្ធិដូចគ្នានេះដែរ ក្នុងការសួរសំណួរលោក ឆាំង យុ ពីបញ្ហានេះ ។

លោកប្រធាន និល ណុន បានទទួលស្គាល់ការបដិសេធនេះ ដោយណែនាំខាងមេធាវីការពារក្តី ឈប់ប្រើអត្ថបទដែលសរសេរដោយបុគ្គលនានាផ្សេងពី លោក ឆាំង យុ ក្នុងពេលលើកជាសំណួរសួរ លោក ឆាំង យុ ។

មេធាវី ប៉ោ ឆ្លើយដោយសួរថាជាទូទៅថាតើមជ្ឈមណ្ឌលឯកសារកម្ពុជាបានជាប់ទាក់ទងនឹងការរៀបរាប់យុត្តាធិការជាបុគ្គលនៃ អ.វ.ត.ក ។ ភ្លាមនោះ ព្រះរាជអាជ្ញាជំទាស់ម្តងទៀតដោយផ្អែកលើហេតុផលដដែល ។

មេធាវី ប៉ោ តបវិញថា ក្រុមមេធាវីការពារមានការបារម្ភថា «ការិយាល័យសហព្រះរាជអាជ្ញាហាក់ដូចជាមិនសូវចាប់អារម្មណ៍សកម្មភាពរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលជាអ្នកខបត្ថម្ភឯកសារដ៏សំខាន់ដល់សាលាក្តីនេះ» ។ លោកបន្ថែមទៀតថា មជ្ឈមណ្ឌលឯកសារកម្ពុជា អាចបញ្ជាក់ថាខ្លួនជាអង្គការសិក្សាស្រាវជ្រាវដែលឯករាជ្យ នេះមិនមែនមានន័យថាវាត្រូវតែជាការពិតទេ ។ មេធាវី ប៉ោ បានបន្តដោយសំអាងថា សារអេឡិចត្រូនិចដែលលោកទើបតែបានពិគ្រោះនោះបានបង្ហាញថា មជ្ឈមណ្ឌលឯកសារកម្ពុជា មានរបៀបវារៈមួយទាក់ទងនឹងជនណាដែលនឹងត្រូវកាត់ទោសដែលត្រូវតែបានរកឃើញ ពីព្រោះ វាជាគោលដៅចម្បងក្នុងការប្រមូលឯកសារនានា ។

ការជំទាស់នេះមានប្រសិទ្ធិភាព ហើយលោកស្រីចៅក្រម ខាតវ្រ៉ាយតិ៍ បានជម្រាបទៅមេធាវីការពារក្តី នួន ជា ថា អង្គជំនុំជម្រះ«យល់យ៉ាងច្បាស់»ពីកម្រងសំណួររបស់ក្រុមមេធាវីការពារ និងការទុទិដ្ឋនិយមពីកិច្ចការប្រមូលឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ប៉ុន្តែចៅក្រមបានឮគ្រប់គ្រាន់ហើយពីបញ្ហាទាំងនេះ ។ លោកស្រីចៅបានរំឭកលោក ប៉ោ បន្ថែមទៀតថា សាក្សីមិនអាចត្រូវចោទសួរឲ្យធ្វើការផ្តល់ជាយោបល់ពីគំនិតរបស់បុគ្គលផ្សេងទៀតបានទេ ។

មេធាវី ប៉ោ បានតបវិញថា លោកនឹងបន្តសំណួរទៅទៀត ប៉ុន្តែលើកឡើងថា នេះជាជំហររបស់ក្រុមមេធាវីការពារ នួន ជា ដែលសំណួរជាច្រើនដែលលើកឡើងមិនទទួលបានចម្លើយ ហើយនិងរក្សាសិទ្ធិក្នុងការប្រកាន់ជំហរនេះបន្តទៀតនៅសវនាការ ។

ត្រង់ចំណុចនេះ លោកស្រីចៅក្រម ខាត់វ្រ៉ាយតិ៍ បានកាត់ និងសួរមេធាវី ប៉ោ ឈប់មួយភ្លែត នៅពេលដែលអង្គជំនុំជម្រះត្រូវការពេលវេលាសម្រាកដោះស្រាយបញ្ហារដ្ឋបាល ។

## អង្គជំនុំជម្រះចេញសេចក្តីប្រកាសលើការដាក់ពាក្យពីពេលមុនដោយក្រុមមេធាវី នួន ជា

បន្ទាប់ពីមានការពិភាក្សារវាងចៅក្រមរួមមក លោកប្រធាន និល ណុន ប្រកាសថា អង្គជំនុំជម្រះនឹងប្រកាសផ្ទាល់មាត់លើការសម្រេចរបស់ខ្លួនទាក់ទងទៅនឹងការដាក់ពាក្យសុំឲ្យអង្គជំនុំជម្រះ

បញ្ឈប់សេចក្តីថ្លែងការណ៍ធ្វើឡើងដោយនាយករដ្ឋមន្ត្រី ហ៊ុន សែន ទាក់ទងនឹងទោសកំហុសរបស់ នួន ជា លោកប្រធានធ្វើការកត់សម្គាល់ថា នេះជាសិទ្ធិរបស់ជនជាប់ចោទទាំងអស់ទទួលបាននូវការសន្មត់ថាគ្មានទោសក្រោមរដ្ឋធម្មនុញ្ញនៃព្រះរាជណាចក្រកម្ពុជា ហើយអង្គជំនុំជម្រះនឹងមិនយកសំដីបុគ្គលណាមួយ មកគិតនៅពេលកាត់ទោសជនជាប់ចោទទេ ។

បន្ទាប់មកប្រធានអង្គជំនុំជម្រះបានប្រកាសសវនាការនឹងផ្អាកត្រឹមប៉ុននេះនៅថ្ងៃនេះ នឹងបន្តនៅថ្ងៃចន្ទ័ ទី៦ ខែកុម្ភៈ ឆ្នាំ២០១២ នៅម៉ោង៩ព្រឹក ហើយលោក ឆាំង យុ នៅតែមានវត្តមាននៅសវនាការដដែល ដើម្បីបន្តធ្វើសក្ខីកម្មរបស់ខ្លួន ។

**-ចប់-**